ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ សរណន

## សារាចរណែនាំ
## ស្តីពី
## ការតែងតាំងមន្ត្រីខុទ្ទកាល័យ និងជំនួយការថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់

អនុលោមតាមព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី អនុក្រឹត្យ លេខ ២០ អនក្រ បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន និងបណ្តាលិខិតបទដ្ឋានផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់កន្លងមក និងដើម្បីគ្រប់គ្រងមន្ត្រីរាជការគ្រប់ប្រភេទឲ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសមន្ត្រីដែលបំពេញមុខងារនៅក្នុងខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់នៅតាមក្រសួង និងស្ថាប័ននានារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី ៥ នៃរដ្ឋសភា ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ សូមធ្វើការណែនាំដូចតទៅ :

១-រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នត្រូវរៀបចំចេញប្រកាសបញ្ចប់តំណែងមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការដែលបំពេញការងារក្នុងសាមី ខុទ្ទកាល័យ - អមសាមី ក្រសួង ស្ថាប័ន និងក្នុងអង្គភាពចំណុះសាមីក្រសួង ស្ថាប័នទាំងអស់ ដែលទទួលបានការតែងតាំងមុនថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ។

២-ក្រោយពីបានបញ្ចប់តំណែងរបស់ជនទាំងអស់ដូចមានចែងក្នុងចំណុចទី ១ ខាងលើ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នអាចរៀបចំតែងតាំងសាជាថ្មី នូវមន្ត្រីខុទ្ទកាល័យ ទីប្រឹក្សា និងជំនួយការឲ្យបំពេញការងារក្នុងសាមីខុទ្ទកាល័យ - អមសាមីក្រសួង ស្ថាប័ន ឡើងវិញស្របតាមអនុក្រឹត្យលេខ ២០ អនក្រ បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

ទទួលបានសារាចរណែនាំនេះ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារខាងលើ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន